# ជំនួយស្មារតី

## លើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ

## ដើម្បីសម្រេចគោលដៅ

## កម្ពុជា : ព្រះរាជាណាចក្រនៃវប្បម៌

**"សុវត្ថិភាព និរន្តរភាព សុខដុមភាព វឌ្ឍនភាព"**

*ឧសភា ២០១១*

# អារម្ភកថា

ស្ថិតក្នុងសមត្ថកិច្ច នៃបណ្ដាបេសកកម្ម ដឹកនាំ និងគ្រប់គ្រងលើវិស័យវប្បធម៌ និងវិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា។ ថ្វីត្បិតថាកន្លងមកយើងតែងសម្រេចបាននូវជោគជ័យជាបន្តបន្ទាប់គួរឱ្យមោទនភាពក៏ពិតមែន។ ក៏ប៉ុន្តែ ក្នុងដំណាក់កាលដែលធនធានសម្បត្តិវប្បធម៌ដ៏សម្បូរបែបរបស់យើង ត្រូវបាននិងកំពុងទទួលរងនូវផលប៉ះពាល់ដោយសារ កត្តាជាច្រើនដូចជា៖ កត្តាសង្គ្រាម កត្តាធម្មជាតិ កត្តាមនុស្ស ភាពចំណាស់នៃប្រាសាទ កត្តាលំហូរ ចូលឥតឈប់ឈរនៃវប្បធម៌អវិជ្ជមានពីបរទេសជាដើមនោះ។ វាពិតជាទាមទារដ៏ចាំបាច់នូវសមត្ថភាព ទេពកោសល្យ កិច្ចប្រតិបត្តិការប្រកបដោយផែនការ ការច្បាស់លាស់ ការបង្កើនសកម្មភាពប្រកបដោយ ការយកចិត្តទុកដាក់ និងស្មារតីទទួលខុសត្រូវខ្ពស់ បំផុតពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រី

រាជការរបស់យើង។ ហេតុនេះហើយ ដើម្បីសម្រេចឱ្យបានជោគជ័យនូវបណ្ដាបេសកកម្ម ផែនការអាទិភាពទាំង៥ និងគោលដៅ **កម្ពុជា : ព្រះរាជាណាចក្រនៃវប្បធម៌** អ្វីៗទាំងអស់ដើម្បី **សុវត្ថិភាព និរន្តរភាព សុខដុមភាព** និង **វឌ្ឍនភាព** វប្បធម៌ នោះសង្គតិភាព នៃអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** ថ្លែងក្នុងឱកាសទិវាវប្បធម៌ជាតិ៣ មីនា លើកទី១៣ ឆ្នាំ២០១១ អនុសាសន៍ **ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ថ្លែងក្នុងពិធីបើកមហោស្រពសិល្បៈមហាជនទូទាំងប្រទេស ឆ្នាំ២០១១ នាសាលសន្និសីទចតុម្មុខ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១ ព្រមទាំងអនុសាសន៍ **លោកជំទាវ ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីប្រចាំការ** ថ្លែងក្នុងពិធីបិទសន្និបាតក្រសួង នាសាលប្រជុំក្រសួង ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១

និងផែនការសកម្មភាពការងារ ដែលសម្រេចដោយអង្គសន្និបាតរបស់ក្រសួង កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ ដែលមាននៅក្នុងកូនសៀវភៅនេះ គឺជាមូលដ្ឋានគ្រឹះ និងជាត្រីវិស័យប្រកបដោយប្រសិទ្ធភាពបំផុត សម្រាប់កិច្ច-ប្រតិបត្តិការលើការងារវិស័យវប្បធម៌ និងវិចិត្រសិល្បៈ។

ខ្ញុំសង្ឃឹម និងជឿជាក់ថា កូនសៀវភៅ ដែលចងក្រងនូវមូលដ្ឋានគ្រឹះដ៏តូចនេះ នឹងអាចក្លាយជាជំនួយស្មារតីប្រចាំខ្លួន ថ្នាក់ដឹកនាំក្រសួងគ្រប់រូប សម្រាប់ជួយដាស់តឿន ក្រើនរំលឹក ដល់មន្ត្រីរាជការរបស់យើងឱ្យកាន់តែយល់ច្បាស់ពី កាតព្វកិច្ចដែលត្រូវបំពេញជាក់ជាពុំខាន។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១១

**រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

# គោលនយោបាយ

អភិរក្ស និងអភិវឌ្ឍវប្បធម៌

# គោលដៅ

## កម្ពុជាៈ ព្រះរាជាណាចក្រនៃវប្បធម៌

## "សុវត្ថិភាព និរន្តរភាព សុខដុមភាព វឌ្ឍនភាព"

# បេសកកម្ម

ដឹកនាំ និងគ្រប់គ្រងវិស័យវប្បធម៌

និងវិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា។

# ផែនការអាទិភាព

១-ជម្រុញឱ្យកម្ពុជា ក្លាយជាមជ្ឈមណ្ឌលផ្សព្វផ្សាយសិល្បៈទស្សនីយភាព

២-ប្រែក្លាយកម្ពុជា ជាដែនដីស្វាគមន៍នៃការថតខ្សែភាពយន្តបរទេស

៣-ជម្រុញឱ្យកម្ពុជា ក្លាយជាទីកន្លែងផ្សព្វផ្សាយផលិតផលសិល្បៈសូនរូប និងសិល្បៈសិប្បកម្មខ្មែរ

៤-ថែរក្សា ការពារ អភិវឌ្ឍតំបន់បេតិកភណ្ឌ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិ

៥-ពង្រឹងពង្រីកសមត្ថភាពស្ថាប័ន ភាពជាដៃគូអភិវឌ្ឍ បង្កើនប្រសិទ្ធភាពការងារ និងសេវា

# អនុសាសន៍
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងទិវាវប្បធម៌ជាតិ លើកទី ១៣
## នាសាលសន្និសីទចតុម្មុខ, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១១

**ទី១.** ការផលិតស្នាដៃសិល្បៈមហាជន ត្រូវតែផ្សារភ្ជាប់ទៅនឹងគោនយោបាយជាតិលើវិស័យវប្បធម៌ ក្នុងនោះ ការយល់ដឹងអំពីគោលនយោបាយជាតិលើវិស័យវប្បធម៌ គឺជាចំណេះដឹងពុំអាចខ្វះបាន និងជាត្រីវិស័យសម្រាប់ អ្នកនិពន្ធ អ្នកដឹកនាំរឿង និងសិល្បករ-សិល្បការិនីទាំងឡាយ។ ការស្វែងយល់ដឹងឱ្យបានទូលំទូលាយ និងស៊ីជម្រៅអំពីគោលនយោបាយ និងយុទ្ធសាស្ត្រជាតិលើវិស័យវប្បធម៌នេះ និងជួយឱ្យអ្នកនិពន្ធ ផលិតស្នាដៃ និងសម្តែងស្របតាមឆន្ទៈសង្គម

ដែលឆ្លុះបញ្ចាំងពីអត្តសញ្ញាណនៃវប្បធម៌ខ្មែរពិតៗ។ ដូច្នេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបន្តផ្តល់ការអប់រំ និងការផ្សព្វផ្សាយអំពីគោលនយោបាយជាតិលើវិស័យវប្បធម៌ ដោយចាំបាច់ត្រូវតែធ្វើឡើងឱ្យបានទូលំទូលាយ ទាំងនៅក្នុងមជ្ឈដ្ឋាននៃម្ចាស់ផលិតកម្ម អ្នកនិពន្ធ អ្នកដឹកនាំរឿង អ្នកបង្កើតស្នាដៃសិល្បៈ មហាជន និងក្នុងចំណោមសិល្បករ-សិល្បការិនីទាំងអស់របស់យើង ។

**ទី២.** រាល់ការផលិតស្នាដៃ ត្រូវគោរពទៅតាមក្បួនខ្នាតរបស់ជាតិ។ ជាការពិត បុព្វបុរសដូនតាយើងបានបង្កើតក្បួនខ្នាតច្រើនឥតគណនាក្នុងការនិពន្ធ ការបង្កើតស្នាដៃសិល្បៈ និងការសម្តែងសិល្បៈ ដោយឆ្លុះបញ្ចាំងពីវប្បធម៌ដ៏ផូរផង់របស់ជាតិខ្មែរ។ ជារួម ក្បួនខ្នាតទាំងអស់នេះហើយ ដែលជាវិធីសម្រាប់បង្កប់ពណ៌សម្បុរ និងអត្តសញ្ញាណរបស់ជាតិយើង។ ការបង្កើត

ស្នាដៃសិល្បៈដោយខុះនូវក្បួនខ្នាត គឺជាការបង្ខូចនូវតម្លៃ និងព្រលឹងនៃសិល្បៈវប្បធម៌ជាតិ។ ដូច្នេះ ខ្ញុំសូមឱ្យម្ចាស់ផលិតកម្ម អ្នកនិពន្ធ អ្នកដឹកនាំរឿង សិល្បករ-សិល្បការិនីទាំងអស់ ត្រូវបន្តខិតខំរៀនសូត្រឱ្យមាំមួនត្រឹមត្រូវតាមក្បួនខ្នាតនៃទម្រង់សិល្បៈនីមួយៗ ទើបយើងអាចថែរក្សាអត្តសញ្ញាណ និងព្រលឹងនៃសិល្បៈវប្បធម៌របស់ជាតិយើងបាន។ យើងទាំងអស់គ្នាត្រូវចាំថា វឌ្ឍនភាពបានមកពីការរៀនសូត្រ ហើយចំណេះដឹងមានតម្លៃណាស់សម្រាប់ការអភិរក្សនិងអភិវឌ្ឍ។ ប្រសិនបើគ្មានចំណេះដឹងឱ្យបានទូលំទូលាយទេនោះ ការអភិវឌ្ឍត្រូវជួបនូវភាពឱនថយ។ យ៉ាងណាមិញសិល្បៈមហាជនយើងក៏ដូច្នេះដែរ។ ទន្ទឹមនឹងនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គួររៀបចំពិធីឱ្យមានជំនួបគ្នារវាងអ្នកនិពន្ធ អ្នកដឹកនាំរឿង សិល្បករ-សិល្បការិនីទាំងឡាយ ដើម្បីបង្កើនកិច្ចពិភាក្សាឱ្យបានច្រើនក្នុង គោលដៅចែករំលែក

ចំណេះដឹង និងបទពិសោធន៍ពីគ្នាតាមស្មារតីយោគយល់ និងអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក។ ជារួម ខ្ញុំយល់ថា វិធីសាស្ត្រនេះនឹងផ្តល់ជាគន្លឹះកែលម្អ ប្រកបដោយភាពស័ក្តិសិទ្ធដល់ការអភិវឌ្ឍតតឈប់ឈរ និងការបង្កើតស្នាដៃថ្មីៗច្រើនថែមទៀត ។

**ទី៣.** បរិមាណត្រូវផ្សារភ្ជាប់នឹងគុណភាព ដែលជាលក្ខណៈសម្បត្តិដ៏ប្រពៃនៃការទទួលស្គាល់ចំពោះការផលិតស្នាដៃសិល្បៈ។ ភាពសាំ គឺជាសត្រូវស្លាប់របស់របស់សិល្បករ។ ក្នុងន័យនេះ បើយើងផលិតបានស្នាដៃច្រើនប៉ុន្តែខ្វះគុណភាព នោះស្នាដៃទាំងនោះក៏ពុំអាចទទួលបានការគាំទ្រពីមហាជនដែរ។ ជាការពិត ការផលិតស្នាដៃឱ្យបានច្រើន គឺជាការចាំបាច់ហើយ ប៉ុន្តែការធ្វើឱ្យស្នាដៃទាំងនោះឱ្យមានគុណភាពខ្ពស់ នៅក្នុងគោលដៅបម្រើដល់ការកម្សាន្តសប្បាយ ប្រកបដោយសេចក្តីថ្លៃថ្នូរដល់សាធារណជន និងការបង្កប់អំពីអប់រំផ្សព្វផ្សាយ

អំពីចំណេះដឹង សម្រាប់ការអភិវឌ្ឍនូវវប្បធម៌ជាតិ គឺកាន់តែសំខាន់ និងចាំបាច់ផងដែរ ។

**ទី៤. ក្រអឺក្រចុះ កុំឱ្យក្រគំនិត** ។ ដូច្នេះការផ្តួចផ្តើមគំនិត គឺជាលក្ខណៈសម្បត្តិពុំអាចខ្វះបានក្នុងការជម្នះភាពក្រីក្រ និងការបង្កើតស្នាដៃ ។ ពិតមែនតែយើងមានសម្បត្តិវប្បធម៌សម្បូណ៌បែប ប៉ុន្តែទាមទារនូវការផ្តួចផ្តើមគំនិតថ្មីៗ ដើម្បីពង្រឹងស្នាដៃថ្មីៗបន្ថែមទៀត។ គំនិតផ្តួចផ្តើម និងច្នៃប្រឌិតថ្មីៗនឹងធ្វើឱ្យយើងអាចគេចចេញពីការចម្លងស្នាដៃអ្នកដទៃ ។ ការចម្លងស្នាដៃអ្នកដទៃ គឺជាបទល្មើសនៃច្បាប់ កម្មសិទ្ធិបញ្ញា ដែលធ្វើឱ្យវិស័យសិល្បៈវប្បធម៌ជាតិយើងពុំអាចរីកចម្រើនបាន។ ប្រាកដណាស់ អ្នកបង្កើតស្នាដៃតែងរៀនសូត្រពីអ្នកដទៃ ប៉ុន្តែគេពុំគួរចម្លងស្នាដៃអ្នកដទៃដោយល្ងិតល្ងង់ ឬ ដកស្រង់របស់គេទាំងស្រុងនោះទេ ។ គេគួរតែដកស្រង់មេរៀនល្អៗរបស់អ្នកដទៃមកពិចារណា ហើយចម្រាញ់

យកធ្វើជាចំណេះដឹងខ្លួនដើម្បីបង្កើតស្នាដៃថ្មី នោះទើបធ្វើឱ្យវិស័យសិល្បៈវប្បធម៌ជាតិ មានការរីកចម្រើនរុងរឿង។

**ទី៥. គួរយកសិល្បៈចិញ្ចឹមសិល្បៈ** ។ ពិតណាស់ថា ធនធានដែលមិនចេះរីងស្ងួតនោះ គឺការឧបត្ថម្ភ ការគាំទ្រ និងការទំនុកបម្រុងរបស់ប្រជាជនចំពោះការរក្សា ការពារ អភិរក្ស និងអភិវឌ្ឍសម្បត្តិធម្មជាតិ។ តាមរយៈនេះ ក្រុមសិល្បៈមហាជនយើង គួរតែខិតខំហាត់ហ្វឹកហ្វឺន និងសម្ដែងឱ្យបានល្អបំផុត ដើម្បីទទួលបានការគាំទ្រពីមហាជន និងប្រជាជន នៅពេលនោះនឹងធ្វើឱ្យវង់សិល្បៈយើងមានប្រជាប្រិយភាព និងធ្វើអាជីវកម្មចិញ្ចឹមខ្លួនឯងដោយងាយ ។

**ទី៦. ការបើកមហោស្រព គឺជាសាលារៀនមួយ** ពីព្រោះថា ពិធីនេះបានផ្ដល់ឱកាសឱ្យសិល្បករបានផ្លាស់ប្ដូរ បទពិសោធន៍ និងរៀនសូត្រពីគ្នាទៅវិញទៅមក

ទាំងការសម្តែងសិល្បៈលើឆាក និងសិល្បៈផ្សេងៗទៀត ដូចជា សិល្បៈចម្លាក់សូនរូប សិល្បៈសិប្បកម្ម ម្ហូបអាហារ ។ល ។ ជាទស្សនវិស័យទៅអនាគត ស្ថាប័នវប្បធម៌គ្រប់លំដាប់ថ្នាក់ គួរតែខិតខំកសាងផែនការរៀបចំបើកមហោស្រពនេះឱ្យបានទៀងទាត់តាមថ្នាក់នីមួយៗ ដូចជាថ្នាក់មូលដ្ឋាន ខេត្ត ថ្នាក់ភូមិភាគ និងថ្នាក់កណ្តាល ដើម្បីបន្តនិរន្តរភាពលើវិស័យសិល្បៈមហាជនទូទាំងប្រទេស ។ ក្នុងនោះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវខិតខំរៀបចំកម្មវិធី ធ្វើវិក្រឹតការក្រុមសិល្បៈមហាជនយើងឱ្យបានជាប់ជាប្រចាំ ដោយមួយឆ្នាំបើកមហោស្រពថ្នាក់មូលដ្ឋាន មួយឆ្នាំបើកមហោស្រពថ្នាក់ភូមិភាគ និងមួយឆ្នាំបើកមហោស្រពថ្នាក់កណ្តាល ។ ប្រសិនបើយើងធ្វើដូច្នេះបាននោះ យើងពិតជាអាចប្រែក្រុមសិល្បៈមហាជនយើងទៅជា ក្រុមសិល្បៈអភិវឌ្ឍន៍ដែលអាចរួម ចំណែកស្ថាបនាបានយ៉ាងពិតប្រាកដនូវ

របស់ប្រទេសនាមជា **មាតុភូមិ** ជា **មជ្ឈមណ្ឌលផ្សព្វផ្សាយវប្បធម៌ជាតិ** និងជា **ព្រះរាជាណាចក្រនៃវប្បធម៌** ។

**ទី៧.** ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវគិតគូរថ្លឹងថ្លែងឱ្យបានគ្រប់ជ្រុងជ្រោយ ចំពោះពាក្យថា ***សុវត្ថិភាពវប្បធម៌*** ដែលពុំមែនសំដៅតែវប្បធម៌អរូបីនោះទេ គឺត្រូវយកចិត្តទុកដាក់ផងដែរចំពោះសុវត្ថិភាពនៃបេតិកភណ្ឌរូបីផងដែរ ពោលគឺត្រូវចាប់អារម្មណ៍ចំពោះការគ្រប់គ្រង ថែរក្សា អភិរក្ស គាំពារ និងជួសជុលបណ្ដាប្រាសាទក្រៅ ពីតំបន់អង្គរ និងតំបន់ប្រាសាទព្រះវិហារដែលកំពុងទទួលរង ឬ ប្រឈមនឹងគ្រោះមហន្តរាយបែកបាក់នោះ។ យ៉ាងហោចណាស់ក្នុងពេលសេដ្ឋកិច្ចជាតិមិនទាន់មានលទ្ធភាពអនុគ្រោះសម្រាប់ការជួសជុល ក៏គួរយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង ឬ គាំពារកុំឱ្យប្រាសាទដែលទ្រុឌទ្រោមទាំងនេះទទួលរងគ្រោះថ្នាក់ធ្ងន់ធ្ងរដោយខ្វះការថែរក្សា និង

ខិតខំរៀបចំបណ្ដាប្រាសាទ និងរមណីយដ្ឋានប្រវត្តិសាស្ត្រ ទាំងអស់ ឱ្យក្លាយទៅជាទីតាំងស្វាគមន៍សម្រាប់បម្រើ ឱ្យវិស័យទេសចរណ៍ជាតិ ។

**ទី៨.** ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវខិតខំ សិក្សាចងក្រងច្បាប់ ស្ដីពី ការគ្រប់គ្រងសម្បត្តិវប្បធម៌ជាតិ ទាំងរូបី និងអរូបី និងត្រូវជំរុញការអនុវត្ត ច្បាប់កម្មសិទ្ធិបញ្ញា និងសិទ្ធិប្រហាក់ប្រហែល ដើម្បី លុបបំបាត់ការលួចចម្លងស្នាដៃអ្នកដទៃ និងការពារស្នាដៃ ថ្មីៗ ដែលជាកម្មសិទ្ធិបញ្ញារបស់សិល្បករ និងអ្នកនិពន្ធ ឬ អ្នកបង្កើតស្នាដៃថ្មីនោះ។

# អនុសាសន៍
# ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ អាន
# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក
# ទីស្តីការគណៈរដ្ឋមន្ត្រី
# ក្នុងពិធីបើកមហោស្រពសិល្បៈមហាជន
# ទូទាំងប្រទេសឆ្នាំ២០១១
# (សាលសន្និសីទចតុមុខ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១១)

ដើម្បីជាទស្សនវិស័យចំពោះមុខ និងទៅអនាគត ស្ថាប័នវប្បធម៌គ្រប់ថ្នាក់ ពិសេសគឺក្រុមសិល្បៈមហាជនយើងទូទាំងប្រទេស គួរខិតខំផ្តោតការយកចិត្តទុកដាក់ខ្ពស់ដល់យុទ្ធសាស្ត្រ គោលនយោបាយ និងផែនការសកម្មភាពដូចខាងក្រោមៈ

១. គួរខិតខំលើកស្ទួយ ការយល់ដឹង អំពី គោលនយោបាយជាតិលើវិស័យសិល្បៈវប្បធម៌ ដែល

ជាត្រីវិស័យដ៏សំខាន់ សម្រាប់ការអនុវត្ត និង អភិវឌ្ឍវប្បធម៌មហាជនយើង។

២. ប្រែក្លាយវប្បធម៌មហាជន ឱ្យទៅជាវប្បធម៌ អភិវឌ្ឍ តាមរយៈការបណ្តុះបណ្តាល ការថែបំប៉ន ការតែងនិពន្ធ ការសំដែង និងការផ្សព្វផ្សាយ។ ទន្ទឹមនឹងនេះ គួរបង្កើនសមត្ថភាពយល់ដឹងរបស់សិល្បៈករមហាជន ដោយផ្សារភ្ជាប់ការសម្តែងទៅនឹងចំណេះដឹងថ្មី វិទ្យាសាស្ត្របច្ចេកទេសថ្មី ខ្លឹមសារថ្មី ដោយចៀសវាងឱ្យបានពីការលួចចម្លងគ្នាទៅវិញទៅមក និងការអប់រំផ្សព្វផ្សាយ អំពីចំណេះដឹងមូលដ្ឋានបន្ថែមទៅលើការបម្រើភាពរីករាយ ប្រកបដោយភាពថ្លៃថ្នូរ។

៣. លើកស្ទួយគំនិតឆ្នៃប្រឌិត ផលិតស្នាដៃថ្មីឱ្យបានច្រើន ហើយត្រូវចេះប្រើប្រាស់ស្នាដៃទាំងនោះ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការសម្តែង ការរកទីផ្សារសម្រាប់ធ្វើអាជីវកម្ម ដែលទង្វើនេះ

គឺពិតជាអាចជំរុញ លើកកម្ពស់ជីវភាពរស់នៅរបស់សិល្បៈករមហាជនបានយ៉ាងពិតប្រាកដ។

៤. ចាំបាច់ត្រូវខិតខំប្រែក្លាយគុណភាពស្នាដៃ និងការសម្តែងឱ្យមានលក្ខណៈជឿនលឿន ទំនើបកម្ម និងទាន់សម័យ។ ប៉ុន្តែការធ្វើទំនើបកម្មស្នាដៃសិល្បៈមហាជន ត្រូវផ្សារភ្ជាប់ឱ្យបានទៅនឹងប្រពៃណីទំនៀមទម្លាប់ វប្បធម៌ និងអត្តសញ្ញាណជាតិ។

៥. ប្រែក្លាយស្នាដៃសិល្បៈវប្បធម៌មហាជន គ្រប់ប្រភេទឱ្យទៅជាផលិតផលវប្បធម៌ ដែលមានគុណប្រយោជន៍ដល់ការថែរក្សា ការពារ ការបង្កបង្កើត និងការអភិវឌ្ឍវប្បធម៌អរូបីរបស់យើង។ ក្នុងទស្សនៈនេះ ស្ថាប័នទទួលបន្ទុក គួរខិតខំពង្រីកសិល្បករអាជីពឱ្យទៅជាគ្រូបង្គោលនៃក្រុមសិល្បៈករមហាជន សម្រាប់ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍវប្បធម៌។ ស្ថាប័នវប្បធម៌ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ត្រូវខិតខំ

កសាងផែនការ និងលើកទិសដៅឱ្យក្រុមសិល្បៈមហាជន អាចមានលទ្ធភាពបង្កើតក្រុមសិល្បៈមហាជនត១គ្នា។ ទន្ទឹមនឹងនេះ យើងត្រូវជម្រុញឱ្យមានការចុះបញ្ជីសារពើភណ្ឌ ពាក់ព័ន្ធនឹងចំនួនក្រុមសិល្បៈមហាជន ទូទាំងប្រទេស ដើម្បីចងក្រងជាទិន្នន័យ សម្រាប់ពង្រឹង និងពង្រីកសិល្បៈមហាជនទាំងនោះ ទាំងបរិមាណ និងគុណភាព។ ម្យ៉ាងទៀតស្ថាប័ន ទទួលបន្ទុកនិងសិល្បៈមហាជន គួរខិតខំចងក្រងឯកសារបោះពុម្ពផ្សាយស្នាដៃសិល្បៈមហាជន និងរក្សាទុក សម្រាប់មនុស្សជំនាន់ក្រោយ។

៦. តែងតាំង និងបង្កើតតួនាទីរបស់គ្រូចាស់ទុំនៅក្នុងក្របខ័ណ្ឌ "**មរតកមនុស្សរស់**" ដើម្បីផ្ទេរចំណេះដឹង តាមរយៈការបើកកម្មវិធីហ្វឹកហ្វឺន និងសម្តែងផ្សព្វផ្សាយជូនសាធារណៈជន ពិសេសយុវជនជំនាន់ក្រោយឱ្យមាន ការយល់ដឹងកាន់តែច្បាស់ អំពីតម្លៃនៃសិល្បៈវប្បធម៌ និងជំរុញ

ការចូលរួមក្នុងការថែរក្សា ការពារមតិកវប្បធម៌មហាជនយើងឱ្យបានគង់វង្សទៅអនាគត ។

៧. រាល់ស្នាដៃសិល្បៈវប្បធម៌មហាជន ចាំបាច់ត្រូវបានទទួលការកែលម្អ និងការលើកសរសើរ ដើម្បីឱ្យរូបភាព និងខ្លឹមសារកាន់តែមានលក្ខណៈមុតស្រួច និងល្អប្រសើរឡើង ហើយការតែងនិពន្ធគួរត្រូវបានលើកទឹកចិត្ត ។

៨. ដើម្បីធានាដល់ការរីកចម្រើន ប្រកបដោយនិរន្តរភាព យើងគួរបង្កើតឱ្យមានមហោស្រពសិល្បៈមហាជន ថ្នាក់មូលដ្ឋានឱ្យបានផុលផុស ក្នុងរយៈពេលពីរឆ្នាំម្តង ដោយប្រើប្រាស់កម្មវិធីហ៊ឹកហ៊ឺនដ៏ជាក់លាក់គឺ មួយឆ្នាំបណ្តុះបណ្តាល មួយឆ្នាំបើកមហោស្រព ថ្នាក់មូលដ្ឋាន និង មួយឆ្នាំទៀតបើកមហោស្រពថ្នាក់ជាតិ ។

# អនុសាសន៍
# លោកជំទាវ ម៉ែន សំអន
# ឧបនាយករដ្ឋមន្ត្រីប្រចាំការ
# ថ្លែងក្នុងពិធីបិទសន្និបាតក្រសួង
# (នាសាលប្រជុំក្រសួង ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១)

ដើម្បីឈានទៅដល់ សម្រេចឱ្យបាន គោលដៅចុងក្រោយ "**កម្ពុជា : ព្រះរាជណាចក្រនៃវប្បធម៌**" ប្រកបដោយជោគជ័យ និងប្រសិទ្ធភាពខ្ពស់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មិនត្រឹមតែត្រូវយកចិត្តទុកដាក់លើសកម្មភាពសិល្បៈវប្បធម៌ និងការបណ្តុះបណ្តាលធនធានក្នុងប្រព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែត្រូវយកចិត្តទុកដាក់ ចាប់អារម្មណ៍ចំពោះសកម្មភាព និងការបណ្តុះបណ្តាលជំនាញសិល្បៈវប្បធម៌ តាមក្រៅប្រព័ន្ធមួយចំនួនដែលមាននៅសេសសល់នៅក្នុងសង្គមកម្ពុជា ដែលជំនាញខ្លះកំពុងប្រឈមមុខនឹងការបាត់បង់នៅពេលអនាគត ដូចជា

ចំណេះជំនាញទាក់ទងនឹងឧបករណ៍តន្ត្រី ម្ហូបអាហារប្រពៃណី សិប្បកម្មត្បាញរវៃ សិល្បៈក្បាច់គុណបុរាណខ្មែរ ក៏ដូចជាការងារសិល្បៈវប្បធម៌ជាច្រើនទៀត។ លើសពីនេះទៅទៀត ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវយកចិត្តទុកដាក់ផងដែរ ចំពោះចំណេះជំនាញផ្សេងៗដែលបង្កប់នៅក្នុងអំបូរជនជាតិដើមភាគតិចរបស់យើង។

ក្នុងន័យនេះ ខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួន ដូចខាងក្រោម ៈ

- រៀបចំតំបន់បេតិកភណ្ឌវប្បធម៌ រមណីយដ្ឋានវប្បធម៌ និងប្រវត្តិសាស្ត្រឱ្យក្លាយជាមណ្ឌលវប្បធម៌ សម្រាប់បម្រើឱ្យគោលដៅទេសចរណ៍ជាតិ និងអន្តរជាតិ
- ខិតខំជំរុញផលិតផលសិល្បៈសូនរូប និងសិប្បកម្មខ្មែរ ឱ្យកាន់តែសម្បូរបែប និងប្រកបដោយគុណភាពដើម្បី ផ្សព្វផ្សាយវប្បធម៌ផង និងបម្រើ វិស័យពាណិជ្ជកម្មផង

- ជំរុញ និងលើកស្ទួយការតែងនិពន្ធ ការសម្តែង និងផ្សព្វផ្សាយសិល្បៈទស្សនីយភាព ឱ្យបានទូលំទូលាយទូទាំងប្រទេស ពិសេសនៅតំបន់ណាដែលមានសក្តានុពលទេសចរណ៍
- ជំរុញការកសាងច្បាប់ និងអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងសម្បត្តិបេតិកភណ្ឌវប្បធម៌ និងច្បាប់សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។ បន្តជំរុញកិច្ចសហការជាមួយបណ្តាប្រសួងស្ថាប័នពាក់ព័ន្ធដូចជាក្រសួងព័ត៌មាន ក្រសួងទេសចរណ៍ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ក្នុងការផ្សព្វផ្សាយ អប់រំ និងទប់ស្កាត់ការ ជួញដូរវត្ថុបុរាណ
- បន្តខិតខំសិក្សាស្រាវជ្រាវ ចងក្រង និងថែរក្សានូវសម្បត្តិបេតិកភណ្ឌវប្បធម៌ ទាំងរូបី និងអរូបី និងទំនៀមទម្លាប់និងសិល្បៈវប្បធម៌របស់ជនជាតិភាគតិច និងជនជាតិដើមភាគតិចនៅកម្ពុជា។

បន្តលើកស្ទួយ ការអនុវត្តច្បាប់ ស្តីពី ប្រព័ន្ធមរតកមនុស្សរស់នៅកម្ពុជា សំដៅថែរក្សា ការពារនូវធនធាន ចំណេះជំនាញដែលកម្រ និងដែលកំពុងប្រឈមនឹងការបាត់បង់

- បន្តសហការយ៉ាងជិតស្និទ្ធជាមួយ អង្គការសហគម និងដៃគូឯកជនទាំងឡាយ ដែលកំពុងប្រតិបត្តិការលើវិស័យសិល្បៈវប្បធម៌ ដើម្បីសហការគ្រប់គ្រង គាំពារ និងអនុវត្តស្របតាមនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាល
- បន្តយកចិត្តទុកដាក់ក្នុងការថែបំប៉ន បណ្តុះ-បណ្តាលធនធានមនុស្ស តាមរយៈការពង្រឹង និងពង្រីកការងារអប់រំ បណ្តុះបណ្តាលនៅក្នុងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាលាមធ្យមសិក្សាវិចិត្រសិល្បៈ។ ត្រូវធ្វើការពង្រឹងសមត្ថភាពដឹកនាំ និងប្រើប្រាស់ធនធានឱ្យបានសមស្របតាមជំនាញ បច្ចេកទេសដោយបែងចែក

និងដាក់ពង្រាយធនធានឱ្យចំគោលដៅ ជាពិសេស សម្រាប់តំបន់ជាប់ព្រំដែន និងតំបន់ខ្វះខាតធនធាន

- បន្តខិតខំសហការជាមួយដៃគូអភិវឌ្ឍន៍ និងផ្នែកឯកជន សំដៅពង្រីកភាពជាដៃគូ និងធ្វើការគៀងគរធនធាន ទាំងធនធានហិរញ្ញវត្ថុ សម្ភារៈ និងធនធានមនុស្ស ដើម្បីរួមចំណែកធ្វើបច្ចុប្បន្នភាពហេដ្ឋារចនាសម្ព័ន្ធវប្បធម៌ និងសមត្ថភាពស្ថាប័ន ឱ្យបានរឹងមាំ និងជឿនលឿនស្របទៅនឹងការរីកចម្រើន ក្នុងតំបន់ និងពិភពលោក
- បន្តបង្កើតគំនិតច្នៃប្រឌិត ដើម្បីរក្សាអត្តសញ្ញាណជាតិ និងធ្វើការកែច្នៃវប្បធម៌ និងសិល្បៈរបស់យើងឱ្យកាន់តែមានភាពរស់រវើក
- បន្តធ្វើការផ្សព្វផ្សាយ និងអប់រំដល់សាធារណជនឱ្យជួយចូលរួមចំណែកលើកស្ទួយវប្បធម៌ សិល្បៈ

និងស្នាដៃរបស់វិចិត្រករ ជាងចម្លាក់របស់យើង តាមរយៈការចូលរួមទស្សនា និងលើកទឹកចិត្ត ដល់សិល្បករ-សិល្បការិនី និងជាវបណ្ណាស្នាដៃទាំងនោះ ។

ក្រៅពីអនុសាសន៍ទាំងនេះ ខ្ញុំក៏សូមអំពាវនាវដល់មន្ត្រី និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវយកផែនការសកម្មភាពដែលទទួលបានពីការពិភាក្សារបស់សន្និបាតនាពេលនេះ ធ្វើជាផែនទីបង្ហាញផ្លូវ សម្រាប់ការធ្វើសកម្មភាពរបស់លោកជំទាវ ឯកឧត្តម លោកស្រី លោក នាងកញ្ញា ទាំងអស់ដែលកំពុងធ្វើការងារ ក្នុងវិស័យវប្បធម៌ ។

# ផែនការសកម្មភាពប្រចាំឆ្នាំ២០១១ ដែលអនុម័តដោយអង្គសន្និបាតក្រសួង (ថ្ងៃទី២៥-២៧ ខែមករា ឆ្នាំ២០១១)

## ១.ការងារបំរើព្រឹត្តិការសំខាន់ៗ

- ប្រារព្ធទិវាវប្បធម៌ជាតិ៣មីនា លើកទី១៣ ឆ្នាំ២០១១
- បើកមហោស្រពសិល្បៈមហាជនទូទាំងប្រទេស
- ប្រារព្ធពិធីបុណ្យខួបអនុស្សាវរីយ៍ ប្រាសាទព្រះវិហារចូលជាបេតិកភណ្ឌពិភពលោក (០៧ កក្កដា ២០០៨ - ០៧ កក្កដា ២០១១)
- ប្រារព្ធពិធីបុណ្យខួបអនុស្សាវរីយ៍ ការចុះបញ្ជីបណ្ណសារសារមន្ទីរទួលស្លែង ជាស្មារតីចងចាំនៃពិភពលោក (៣១កក្កដា ២០០៩-៣១កក្កដា ២០១១)

- ប្រារព្ធពិធីបុណ្យខួបអនុស្សាវរីយ៍ល្ខោនស្រមោលស្បែកធំចូលជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ (២៥ វិច្ឆិកា ២០០៥ -២៥ វិច្ឆិកា ២០១១)
- ប្រារព្ធពិធីបុណ្យខួបអនុស្សាវរីយ៍ របាំក្បាច់បុរាណ ឬ របាំព្រះរាជទ្រព្យ ចូលជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ(០៧ វិច្ឆិកា ២០០៣ - ០៧ វិច្ឆិកា ២០១១)
- ប្រារព្ធពិធីបុណ្យខួបអនុស្សាវរីយ៍ រមណីយដ្ឋានអង្គរចូលជាបេតិកភណ្ឌពិភពលោក (១៤ ធ្នូ ១៩៩២ - ១៤ ធ្នូ ២០១១) ។

## ២.ការងារអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌

### ២.១.ការងារសិល្បៈទស្សនីយភាព

- រៀបចំបើកមហោស្រពសិល្បៈទូទាំងប្រទេស
- ពង្រឹងសមត្ថភាពជំនាញ និងជួយកែលម្អស្នាដៃសិល្បៈមហាជន និងអង្គការ សមាគមសិល្បៈ

- សិក្សាស្រាវជ្រាវ ចងក្រង និងតម្លើងស្នាដៃសិល្បៈទស្សនីយភាព និងតន្ត្រីបុរាណសម្រាប់តម្កល់ទុកជាឯកសារបម្រើដល់ការអប់រំផ្សព្វផ្សាយ
- ធ្វើបឋកថាអំពីសិល្បៈទស្សនីយភាព និងតន្ត្រីបុរាណខ្មែរនៅតាមសាលាចំណេះទូទៅ
- រៀបចំកម្មវិធីសម្តែងសិល្បៈទស្សនីយភាពឱ្យបានជាប់ជាប្រចាំ ជូនទស្សនិកជនជាតិ និងអន្តរជាតិនៅរាជធានីភ្នំពេញ
- ត្រៀមសម្តែងសិល្បៈទស្សនីយភាព បម្រើព្រឹត្តិការណ៍សំខាន់ៗ និងចូលរួមក្នុងសកម្មភាពនៅលើឆាកអន្តរជាតិ
- រៀបចំឱ្យបានសម្រេចនូវអនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសិល្បៈទស្សនីយភាព។

## ២.២.ការងារសិល្បៈភាពយន្ត និងផ្សព្វផ្សាយ វប្បធម៌

- ផ្តល់ទិដ្ឋាការ អាជ្ញាប័ណ្ណ និងសេវាកម្មលើផ្នែកអាជីវកម្មភាពយន្ត-វីដេអូ

- ផ្សព្វផ្សាយព័ត៌មានវិស័យភាពយន្ត វីដេអូ តាមគ្រប់មធ្យោបាយ ដើម្បីទាក់ទាញការថតភាពយន្តនៅកម្ពុជា
- ពង្រឹងសមត្ថភាព អ្នកជំនាញបច្ចេកទេសដែលមានការទាក់ទងនឹងវិស័យភាពយន្ត-វីដេអូ
- សហការអនុវត្តការងារត្រួតពិនិត្យ បទល្មើសភាពយន្ត-វីដេអូ ជាមួយគណៈកម្មការអន្តរក្រសួង បង្ក្រាបបទល្មើសភាពយន្ត-វីដេអូ
- ផលិតវិដេអូឯកសារ បទយកការណ៍ និងព័ត៌មានផ្សេងៗ ដែលទាក់ទងដល់វិស័យវប្បធម៌ដើម្បីផ្សព្វផ្សាយ និងទុកជាឯកសារ
- បង្កើនការអភិរក្សឯកសារភាពយន្ត-វីដេអូ

## ២.៣.ការងារសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

- បន្តធ្វើស្ថិតិសហគ្រាសវប្បធម៌ ផ្នែកសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

- បណ្តុះបណ្តាល អំពី ក្បួនខ្នាតក្បាច់ចម្លាក់ខ្មែរ ដល់សហគមន៍ សមាគម និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ
- ពង្រឹងកិច្ចសហការជាមួយ ដៃគូឯកជន អង្គការ សមាគម និងរោងជាងផលិតដើម្បីពង្រឹង គុណភាព សោភ័ណភាពផលិតផលសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម
- រៀបចំមហោស្រពសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម
- រៀបចំឱ្យបានសម្រេចនូវអនុក្រឹត្យ ស្តីពី ការគ្រប់គ្រងសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

## ២.៤.ការងារអភិវឌ្ឍន៍វប្បធម៌

- រៀបចំមហោស្រពបង្ហើរខ្លែង សិល្បៈដណ្តាំស្លម្ហូបអាហារខ្មែរ និងទម្រង់សម្លៀកបំពាក់
- សិក្សាស្រាវជ្រាវ ចងក្រងអំពីក្បាច់គុណខ្មែរ

- សិក្សាស្រាវជ្រាវ និងចងក្រងឯកសារអំពីប្រពៃណីជនជាតិដើមភាគតិច
- សិក្សាស្រាវជ្រាវ និងបោះពុម្ពសៀវភៅ ដើម្បីផ្សព្វផ្សាយអំពី ទំនៀមទម្លាប់នៃការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងសិល្បៈដណ្តាំស្លម្ហូបអាហារខ្មែរ
- រៀបចំអនុក្រិត្យ ស្តីពី ការគ្រប់គ្រងត្រួតពិនិត្យការធ្វើអាជីវកម្ម និងសេវាកម្មវប្បធម៌

## ២.៩.ការងារសៀវភៅ និងការអាន

- ប្រឡងជ្រើសរើសស្នាដៃតែងនិពន្ធ ប្រលោមលោក កំណាព្យស្តីពី **"សុវត្ថិភាពវប្បធម៌ដើម្បីអភិវឌ្ឍ សេដ្ឋកិច្ចជាតិ"**
- ពង្រឹងពង្រីកសកម្មភាពបណ្ណាល័យចល័ត តាមមូលដ្ឋាន ដើម្បីបណ្តុះពុទ្ធិលើវិស័យការអានដល់សាធារណៈជន

- ស្រង់ស្ថិតិបណ្ណាល័យទូទាំងប្រទេស និងបន្តធ្វើគន្ថនិទ្ទេសជាតិ
- បន្តការថតចម្លង (ការស្កេន) សៀវភៅចាស់ៗ និងបោះពុម្ពផ្សាយឡើងវិញ
- បណ្តុះបណ្តាលជំនាញបណ្ណាល័យ និងការបោះពុម្ពផ្សាយ
- រៀបចំពិព័ណ៌ផ្សព្វផ្សាយសៀវភៅ និងចូលរួមក្នុងទិវានៃការអាន
- រៀបចំបង្កើតគេហទំព័របណ្ណាល័យជាតិ ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយ
- កសាងច្បាប់ស្តីពីការគ្រប់គ្រងបណ្ណាល័យ ។

## ២.៦.ការងារមតិកមនុស្សរស់

- គាំពារ និងលើកកម្ពស់ធនធានមតិកមនុស្សរស់នៅទូទាំងប្រទេស ដោយបង្កើតយន្តការសម្រាប់

- បង្កើតប្រព័ន្ធសម្រាប់បន្តវេន និងផ្ទេរចំណេះដឹង ជំនាញ ទេពកោសល្យ និង បច្ចេកទេសដល់អ្នកជំនាន់ក្រោយ
- សិក្សស្រាវជ្រាវ និងចងក្រងបញ្ជីសារពើភណ្ឌនៃបេតិកភណ្ឌវប្បធម៌អរូបី
- សិក្សា ចងក្រងឯកសារចំណេះដឹង ជំនាញ បច្ចេកទេសនិងស្នាដៃរបស់មតិកមនុស្សរស់
- ផ្សព្វផ្សាយស្នាដៃមតិកមនុស្សរស់ ។

# ៣.ការងារអគ្គនាយកដ្ឋានបេតិកភណ្ឌ

## ៣.១.ការងារគាំពារ និងអភិរក្សសំណង់បុរាណ

- បន្តសហការជាមួយ CMAC CMAA បោស-សំអាតយុទ្ធភណ្ឌមិនទាន់ផ្ទុះ នៅតំបន់ប្រាសាទ និងស្ថានីយបុរាណ

- ធ្វើការសង្គ្រោះ ទល់ទ្រប្រាសាទបុរាណ ដែលកំពុងប្រឈមនឹងគ្រោះថ្នាក់រកកលដួលរលំ
- បន្តសហការជាមួយអង្គការមូលនិធិបេតិកភណ្ឌពិភពលោក Global Heritage Fund ជួសជុលប្រាសាទបន្ទាយឆ្មារ
- បន្តសហការជាមួយសាកលវិទ្យាល័យWASEDA ជួសជុលប្រាសាទសំបូរព្រៃគុក
- បន្តទំនាក់ទំនងជាមួយស្ថានទូតអាមេរិក ដើម្បីស្នើសុំមូលនិធិ សម្រាប់ជួសជុលប្រាសាទស្នឹង នៅខេត្តបាត់ដំបង
- បន្តជួសជុលស្ពានហាលខាងត្បូង នៃប្រាសាទបន្ទាយឆ្មារនិងព្រះវិហារវត្តកំពុងត្រឡាចលើ
- សិក្សារៀបចំឯកសារដើម្បីសុំបញ្ចូលប្រាសាទបន្ទាយឆ្មារ និងសំបូរព្រៃគុក ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

- កសាងប្លង់មេលើរមណីយដ្ឋានដែលត្រូវ ជម្រុញការអភិវឌ្ឍ

## ៣.២.ការងារបុរាណវិទ្យា និងបុរេប្រវត្តិវិទ្យា

- បន្តទំនាក់ទំនងជាមួយ អាជ្ញាធរដែនដី រដ្ឋបាលសុរិយោដី ដើម្បីស្នើសុំបណ្ណកម្មសិទ្ធទីតាំងស្ថានីយបុរាណ
- ជួសជុល និងតម្លើងវត្ថុសិល្បៈបានពីកំណាយសម្រាប់ដាក់តាំងបង្ហាញ
- ស្រង់ស្ថិតិប្រាសាទបុរាណ ទួលបុរាណ វត្ថុបុរាណនៅតាមស្ថានីយបុរាណ
- សហការជាមួយអជ្ញាធរដែនដី មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី/ខេត្ត ដើម្បីបោះស្លាកសញ្ញាសំគាល់ទីទួលបុរាណ

- អប់រំផ្សព្វផ្សាយច្បាប់ បទដ្ឋានគតិយុត្ត សំដៅពង្រឹងការការពារ ថែរក្សាសម្បត្តិបេតិកភណ្ឌវប្បធម៌ជាតិ

## ៣.៣.ការងារសារមន្ទីរ

- ពង្រឹងគុណភាពផ្នែកបច្ចេកទេសនៅសារមន្ទីរជាតិ និងសារមន្ទីរនៅតាមបណ្តាខេត្ត
- បង្កើនសកម្មភាពជួសជុលវត្ថុបុរាណ
- កសាងវិធានការគ្រប់គ្រង និងអភិរក្សមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
- ធ្វើឱ្យប្រសើរឡើងនូវការបំរើសេវាសារមន្ទីរជូនសាធារណៈជនចូលទស្សនា
- បន្តធ្វើបញ្ជីសារពើភណ្ឌវត្ថុសិល្បៈ និងសមុច្ច័យសារមន្ទីរតាមប្រព័ន្ធកុំព្យូទ័រ

- ពង្រឹងពង្រីកសមត្ថភាពមគ្គុទ្ទេសក៏ និងរៀបចំខ្សែទស្សនាចរឱ្យកាន់តែប្រសើរឡើង
- ស្វះស្វែងរកជំនួយមូលនិធិអន្តរជាតិ ដើម្បីកសាងសារមន្ទីរជាតិពន្ធុវិទ្យានៅក្នុងតំបន់CLV/ DTV

## ៣.៤.ការងារបុរាណវត្ថុ

- បង្កើនសមត្ថភាពគ្រប់គ្រង ត្រួតពិនិត្យ និងផ្តល់សេវាកម្មការនាំចេញ នាំចូលវត្ថុសិល្បៈ
- ធ្វើស្លាកសញ្ញាផ្សព្វផ្សាយពី បណ្តាវិធាន និងទោសទណ្ឌដែលទាក់ទងនឹងការនាំចេញ នាំចូលវត្ថុបុរាណដោយខុសច្បាប់ ដាក់នៅតាមខណ្ឌ/ក្រុង/ស្រុក និងច្រកអន្តរជាតិ
- សិក្សាស្រាវជ្រាវ ចងក្រងអំពីវត្ថុបើប្រាស់មានលក្ខណៈបុរាណរបស់ជនជាតិដើមភាគតិច

- ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកការពារវត្ថុ-បុរាណ ដោយផ្តោតលើវិធីសាស្ត្រការ ស្រង់ស្ថិតិ និងកំណត់ត្រាព័ត៌មានវត្ថុបុរាណ។

## ៤.ការងារសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

- ពង្រឹងនិងពង្រីកគុណភាពការងារបណ្តុះបណ្តាលធនធានមនុស្ស ក្នុងវិស័យសិល្បៈវប្បធម៌ឱ្យកាន់តែរីកចម្រើន និងស្រូបយកធនធាននិស្សិតឱ្យបានកាន់តែច្រើនថែមទៀត
- រៀបចំ និងបង្កលក្ខណៈសម្បត្តិគ្រប់បែបយ៉ាងដើម្បីអោយផ្នែកភាពយន្តនៃមហា វិទ្យាល័យនាដសាស្ត្រ បានដំណើរការនៅ ក្នុងឆ្នាំសិក្សា ២០១១-២០១២
- ជំរុញអោយអនុក្រិត្យបំពេញបន្ថែមលើអនុក្រិត្យលេខ ៥២ អនក្រ. ចុះថ្ងៃទី២៣ ខែមិថុនា

ឆ្នាំ២០០៣ ដើម្បីឱ្យសាកលវិទ្យាល័យ មានមូលដ្ឋានបង្អែកគ្រប់គ្រាន់ ក្នុងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង

- បង្កើតកម្មវិធីបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិត
- ផ្តល់សញ្ញាបត្របរិញ្ញាបត្រ និងបណ្ឌិត កិត្តិយសជូនព្រឹទ្ធាចារ្យសិល្បៈចាស់ៗ ។

## ៥.ការងារសាលាមធ្យមវិចិត្រសិល្បៈ

- បន្តនីតិវិធីជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីស្នើសុំកាន់កាប់សាលាឱ្យស្របច្បាប់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- រៀបចំកម្មវិធីសិក្សាស្របតាមស្តង់ដាររបស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំស្រាវជ្រាវ ចងក្រង និងបោះពុម្ពសៀវភៅអប់រំសិល្បៈគ្រប់ភូមិសិក្សា

- បន្តស្រាវជ្រាវចងក្រងកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ដើម្បីទុកជាឯកសារបច្ចេកទេសសិល្បៈ
- បណ្តុះបណ្តាល និងបង្កើនសមត្ថភាពលើការងារអភិរក្ស និងអភិវឌ្ឍជំនាញសិល្បៈ គ្រប់ទម្រង់
- រៀបចំសាលពិពណ៌អចិន្ត្រៃយ៍រួមមួយដែលបង្ហាញនូវសកម្មភាព និងស្នាដៃរបស់សិស្ស និងគ្រូសំរាប់បង្ហាញជូនដល់សាធារណជនទូទៅទស្សនា។

# ៦.ការងារអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

## ៦.១.ការងាររដ្ឋបាល

- បន្តគ្រប់គ្រង សម្របសម្រួល និងចរាចរលិខិតរដ្ឋបាលឱ្យទាន់ពេលវេលា និងកាន់តែមានប្រសិទ្ធភាព "ច្រកចេញចូលតែមួយ "
- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា និងផ្សព្វផ្សាយវិស័យវប្បធម៌តាមប្រព័ន្ធអ៊ីនធឺណែត
- រៀបចំឱ្យដំណើរការឡើងវិញនូវប្រព័ន្ធNetwork ក្នុងក្រសួង។

## ៦.២.ការងារបុគ្គលិក

- បន្តពង្រឹងការងារគ្រប់គ្រងមន្ត្រីរាជការ តាមបណ្ដាអង្គភាព នាយកដ្ឋាន និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី/ខេត្ត សំដៅលើកកម្ពស់ក៏រិតទិន្នផលការងារ និងជំនាញវិជ្ជាជីវៈនៅក្នុងមុខងារនីមួយៗ
- រៀបចំបំពេញបែបបទ និងនីតិវិធីក្នុងការស្នើសុំការតែងតាំង ប្រគល់ភារកិច្ច ផ្ដល់គ្រឿងឥស្សរយស តម្លើងឋានន្តរស័ក្ដ តម្លើងកាំប្រាក់រំកិលប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការ និងដាក់មន្ត្រីរាជការដែលដល់អាយុឱ្យចូលនិវត្តន៏ ស្របតាមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- រៀបចំបែបបទ ប្រឡងជ្រើសរើសមន្ត្រីរាជការចូលក្របខណ្ឌ ដោយផ្ដោតសំខាន់ទៅលើក្របខណ្ឌ រាជធានី/ខេត្ត ក្រុង/ ស្រុក/ខណ្ឌ។

## ៦.៣.ការងារនីតិកម្ម

- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដោយសហការជាមួយអង្គភាពជំនាញ ផ្តោតសំខាន់ទៅលើបណ្តាវិធានទាំងឡាយ សំដៅបំរើឱ្យសម្រេចបាននូវគោលនយោបាយ គោលដៅ បេសកកម្ម និងផែនការអាទិភាពរបស់ក្រសួង។

## ៦.៤.ការងារផែនការ ស្ថិតិ និងសរុប

- រៀបចំកសាងផែនការយុទ្ធសាស្ត្ររយៈពេលពាឆ្នាំ ២០១២-២០១៥ និងកសាងផែនការសកម្មភាពការងារវប្បធម៌ឆ្នាំ២០១២
- លើកគំរោងផែនការវិនិយោគសាធារណៈ ទៅតាមគោលការណ៍របស់ក្រុមប្រឹក្សាអភិវឌ្ឍជាតិ (CDC)និងរៀបចំផែនការវិនិយោគសាធារណៈពាឆ្នាំរំកិល (PIP)

- ធ្វើរបាយការណ៍ បូកសរុបលទ្ធផលសកម្មភាពការងារវិស័យវប្បធម៌តាមរបបកំណត់
- ប្រមូលទិន្នន័យ ស្ថិតិវិស័យវប្បធម៌នៅតាមរាជធានី/ខេត្តទាំង២៤ ដើម្បីចងក្រង បោះពុម្ពសៀវភៅស្ថិតិវប្បធម៌ឆ្នាំ២០១១ និងសៀវភៅស្តីពីសមិទ្ធផលវិស័យវប្បធម៌ ឆ្នាំ២០១១

## ៦.៥.ការងារសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល

- ពង្រឹងសមត្ថភាពការងារ ការផ្តល់សេវា និងរៀបចំលិខិតបទដ្ឋានគតិយុត្ត ដែលទាក់ទងទៅនឹងវិស័យសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- អប់រំផ្សព្វផ្សាយ អំពីផលប្រយោជន៍នៃការការពារសិទ្ធិអ្នកនិពន្ធ
- រៀបចំឱ្យបានសម្រេចសេចក្តីព្រាងអនុក្រឹត្យ ស្តីពីអង្គភាពសិទ្ធរួម។

## ៦.៦.ការងារសហប្រតិបត្តិការវប្បធម៌អន្តរជាតិ និងកិច្ចការអាស៊ាន

- រៀបចំទទួលគណៈប្រតិភូថ្នាក់រដ្ឋមន្ត្រី មន្ត្រីជំនាញ និងសិល្បករដែលអញ្ជើញមកធ្វើទស្សនកិច្ចផ្លូវការ ស្របតាមកិច្ចព្រមព្រៀងទ្វេភាគីលើកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរវប្បធម៌
- រៀបចំនីតិវិធី សម្រួលដំណើរគណៈប្រតិភូ ថ្នាក់ដឹកនាំក្រសួង មន្ត្រីជំនាញ និងសិល្បករទៅធ្វើទស្សនកិច្ចសិក្សាស្វែងយល់ និងចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗនៅក្នុងតំបន់ និងពិភពលោក
- ធ្វើទំនាក់ទំនង និងសម្របសម្រួលជាមួយរដ្ឋជាសមាជិកអាស៊ានក្នុងការរៀបចំ លើកគម្រោង និងអនុវត្តគម្រោងនានា ក្នុងក្របខណ្ឌអនុគណៈកម្មការវប្បធម៌អាស៊ាន
- សម្របសម្រួលជាមួយបណ្តាដៃគូអភិវឌ្ឍនានា មានដូចជា សមាគម អង្គការក្រៅរដ្ឋាភិបាល និង

អង្គការអន្តរជាតិ ដើម្បីចូលរួមជួយលើកកម្ពស់ ថែរក្សាបេតិកភណ្ឌវប្បធម៌រូបី និងអរូបី និង ជួយផ្សព្វផ្សាយឱ្យមានការយល់ដឹងអំពីវប្បធម៌ ខ្មែរ ស្របតាមគោលនយោបាយ **កម្ពុជា : ព្រះរាជាណាចក្រ នៃវប្បធម៌** ។

## ៦.៧.ការងារគណនេយ្យ និងហិរញ្ញវត្ថុ

- សហការជាមួយនាយកដ្ឋានផែនការ ស្ថិតិ និង សរុប ដើម្បីរៀបចំកសាងផែនការយុទ្ធសាស្ត្រ ថវិកា ៣ឆ្នាំ ២០១២-២០១៥ និងរៀបចំ គ្រោងថវិកាប្រចាំឆ្នាំ ២០១២
- រៀបចំអនុវត្ត និងវិភាជថវិកាប្រចាំឆ្នាំរបស់ ក្រសួង ស្របតាមការងារកែទម្រង់ ការ គ្រប់គ្រងហិរញ្ញវត្ថុ សំដៅឱ្យដំណើរការផែនការ

សកម្មភាពប្រចាំឆ្នាំរបស់ក្រសួង ទទួលបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលការងារខ្ពស់។

## ៦.៨.ការងារសម្ភារៈ-បរិក្ខារ

- រៀបចំកសាង និងអនុវត្តគម្រោងផែនការកិច្ចការលទ្ធកម្មប្រចាំឆ្នាំរបស់ក្រសួង
- ធានាដល់ការផ្គត់ផ្គង់សម្ភារៈបរិក្ខារ និងសម្ភារៈផ្សេងៗ ជូនអង្គភាពក្រោមឱវាទក្រសួង
- រៀបចំបែបបទដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង
- បំពេញបែបបទ និងនីតិវិធីក្នុងការស្នើសុំថវិកាដើម្បីធ្វើការជួសជុល និងកសាងហេដ្ឋារចនាសម្ព័ន្ធវប្បធម៌។

## ៦.៩.ការងារបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌

- រៀបចំបើកវគ្គបណ្តុះបណ្តាល សំដៅពង្រឹងសមត្ថភាពមន្ត្រីរាជការ និងការផ្តល់សេវាសាធារណៈក្នុងវិស័យវប្បធម៌ និងវិចិត្រសិល្បៈ

## ៦.១០.ការងារយេនឌ័រ

- បើកវគ្គបណ្តុះបណ្តាលអំពីទស្សនៈ នៃការវិភាគការបញ្ជ្រាបយេនឌ័រដល់មន្ត្រីរាជការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ នៅសាលាមធ្យមវិចិត្រសិល្បៈ និងនៅសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងមន្ត្រីរាជការនៅក្រោមឱវាទក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

# ៧.ការងារសវនកម្មផ្ទៃក្នុង

- ចុះធ្វើសវនកម្មនៅតាមបណ្តាអង្គភាពជុំវិញក្រសួង ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងសេវា

- ធ្វើរបាយការណ៍ ស្តីពីការអនុវត្តន៍សវនកិច្ច នៅតាមបណ្តាអង្គភាពក្រោមឱវាទក្រសួង និងបណ្តារាជធានី/ខេត្ត ជូនរដ្ឋមន្ត្រី និងផ្ញើទៅអាជ្ញាធរសវនកម្មជាតិ
- បើកវគ្គបណ្តុះបណ្តាលជំនាញសវនកម្មដល់សវនករ

## ៨.ការងារអធិការកិច្ច

- ធ្វើអធិការកិច្ចអង្គភាព និងមន្ទីរក្រោមឱវាទក្រសួង ព្រមទាំងបណ្តាអាជីវកម្ម សេវាកម្ម និងការផ្សព្វផ្សាយវិស័យវប្បធម៌ និងសិល្បៈ
- អង្កេតស្រាវជ្រាវបណ្តឹងវិវាទរដ្ឋបាលនិងបទល្មើសផ្សេងៗ ដែលជាសមត្ថកិច្ចរបស់ក្រសួង។

## ៩.ការងារបង្ក្រាបបទល្មើសភាពយន្ត-វីដេអូ

- បន្តអនុវត្តការងារត្រួតពិនិត្យការធ្វើអាជីវកម្មភាពយន្ត-វីដេអូ សំដៅកាត់បន្ថយបទល្មើសភាពយន្ត-វីដេអូ
- បន្តការងារចុះបង្ក្រាបការបញ្ចាំងខ្សែភាពយន្ត ឬវីដេអូអាសអាភាសនៅទូទាំងប្រទេស។

## ១០.ការងារមន្ទីររាជធានី-ខេត្ត

- បង្កើនការងារគ្រប់គ្រង ចុះបញ្ជីសារពើភណ្ឌចលនទ្រព្យ អចលនទ្រព្យ នៅមូលដ្ឋានរបស់ខ្លួនឱ្យបានត្រឹមត្រូវដើម្បីធានាដល់ការគ្រប់គ្រង
- រៀបចំធ្វើប្លង់កាន់កាប់អាគាររដ្ឋបាល អាគារសាធារណៈរបស់មន្ទីររាជធានី/ខេត្ត
- ទំនាក់ទំនងការងារជាមួយកម្មវិធីវិនិយោគ ដែលមានក្នុងមូលដ្ឋាន ដើម្បីរកមូលនិធិអភិរក្ស និងអភិវឌ្ឍវប្បធម៌នៅរាជធានី/ខេត្ត

- ចូលរួមរៀបចំព្រឹត្តិការណ៍វប្បធម៌ និងបង្កើនសកម្មភាពការងារវប្បធម៌នៅតាមខេត្ត ពិសេសខេត្តតាមបណ្តោយព្រំដែន
- សហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីបន្តធ្វើប្លង់កាន់កាប់ ការពារប្រាសាទ ទួលបុរាណស្រះបុរាណ ស្ថានីយបុរេប្រវត្តិវិទ្យា និងបន្តបោះបង្គោលសម្គាល់ និងកំណត់ទីតាំងតំបន់ត្រូវការពារ
- បង្កើនសមត្ថភាពត្រួតពិនិត្យវត្ថុសិល្បៈនាំចេញ
- គ្រប់គ្រងរមណីយដ្ឋានដែលនៅឆ្ងាយៗ និងទប់ស្កាត់ការលួចជីកកាយ និងការធ្វើកំណាយដោយខុសច្បាប់
- បន្តស្រាវជ្រាវ រុករកប្រាសាទដែលកប់បាត់នៅមូលដ្ឋានដាច់ស្រយាល ។

## លទ្ធផលរំពឹងទុក

អនុវត្តសម្រេចបានតាមផែនការសកម្មភាពខាងលើ យើងសង្ឃឹមថានឹងទទួលបាននូវលទ្ធផលជាវិជ្ជមាន ស្របតាមការរំពឹងទុកដូចតទៅ:

- កម្ពុជានឹងក្លាយទៅជាទីដែលមានសកម្មភាពសិល្បៈទស្សនីយភាពប្រកបទៅដោយសមត្ថភាព និងអត្តសញ្ញាណជាតិរស់រវើកគ្រប់ទីកន្លែង ដែលអាចទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិចូលមកទស្សនាប្រកបដោយនិរន្តរភាព
- ទាក់ទាញបាននូវម្ចាស់ផលិតកម្មភាពយន្តបរទេសនានា ឱ្យចូលមកថតភាពយន្តវីដេអូនៅក្នុងប្រទេសកម្ពុជា
- សិល្បៈវប្បធម៌ជាតិនឹងត្រូវបានផ្សព្វផ្សាយទូទាំងពិភពលោក
- ទប់ស្កាត់ និងកាត់បន្ថយបាននូវលំហូរចូលវប្បធម៌អវិជ្ជមានពីបរទេស

- ថែរក្សា និងការពារសម្បត្តិវប្បធម៌បានប្រកបដោយសុវត្ថិភាព
- ថែរក្សា និងលើកស្ទួយបាននូវវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងភាសារបស់បងប្អូនជនជាតិដើមភាគតិច
- សម្បត្តិវប្បធម៌ និងក្លាយជាកម្លាំងចលករប្រកបដោយប្រសិទ្ធភាពក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ
- សម្បត្តិវប្បធម៌យើងនឹងទទួលបាននូវ **សុវត្ថិភាព សុខដុមភាព និរន្តរភាព និងវឌ្ឍនភាព**
- យើងនឹងសម្រេចបាននូវគោលដៅ **កម្ពុជា : ព្រះរាជាណាចក្រនៃវប្បធម៌ ។**

# ប្រវត្តិទិវាវប្បធម៌ជាតិ ៣មីនា

| ទិវាវប្បធម៌ | ប្រធានបទ | ឆ្នាំប្រារព្ធ |
|---|---|---|
| លើកទី ១ | ស្នាព្រះហស្តព្រះបាទជ័យវរ្ម័នទី៧ | ១៩៩៩ |
| លើកទី ២ | ការថែរក្សា ការពារបេតិកភណ្ឌ | ២០០០ |
| លើកទី ៣ | អភិវឌ្ឍសង្គមវប្បធម៌សន្តិភាព | ២០០១ |
| លើកទី ៤ | អភិរក្សនិងអភិវឌ្ឍវប្បធម៌ដើម្បីសមធម៌សង្គម | ២០០២ |
| លើកទី ៥ | លើកតម្លៃវប្បធម៌ជាតិក្នុងការអភិវឌ្ឍសង្គម | ២០០៣ |
| លើកទី ៦ | របាំក្បាច់បុរាណឬរបាំព្រះរាជទ្រព្យ ជាសម្បត្តិបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ | ២០០៤ |
| លើកទី ៧ | អក្សរសាស្ត្រខ្មែរ ជាអត្តសញ្ញាណជាតិខ្មែរ | ២០០៥ |
| លើកទី ៨ | ល្ខោនស្រមោលស្បែកធំ ជាសម្បត្តិបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ | ២០០៦ |
| លើកទី ៩ | សីលធម៌ និងការអភិវឌ្ឍសង្គម | ២០០៧ |
| លើកទី ១០ | សីលធម៌ និងការអភិវឌ្ឍសង្គម | ២០០៨ |
| លើកទី ១១ | បេតិកភណ្ឌវប្បធម៌និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ | ២០០៩ |
| លើកទី ១២ | ប្រាសាទព្រះវិហារជាទីសក្ការៈជាស្នាដៃឯកជនរបស់ខ្មែរ និង ជាបេតិកភណ្ឌពិភពលោក | ២០១០ |
| លើកទី១៣ | អ្វីៗទាំងអស់ដើម្បីសុវត្ថិភាពវប្បធម៌ | ២០១១ |